**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

# សូមគោរពជូន
# លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
# និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**តាមរយៈ÷** - ឯកឧត្តម ឧត្តមសេនីយ៍ឯក ខៀវ ចាន់រ៉ា អគ្គលេខាធិការរង គ.ជ.ប.ជ និងជាប្រធានក្រុមការងាររបាយការណ៍ ដឹកជញ្ជូន និងរៀបចំ

- **លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**កម្មវត្ថុ÷** ស្ដីពី ពិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៣ និងលើទិសដៅការងារឆ្នាំ២០២៤ ។

ថ្ងៃពុធ ៣ រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ០៧:៣០ នាទីព្រឹក នៅទីស្ដីការក្រសួងមហាផ្ទៃ បានប្រារព្ធពិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ។

## I.សមាសភាពចូលរួម

១.លោកជំទាវ កិត្តិបណ្ឌិត **អ៊ីង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាអនុប្រធាន គ.ជ.ប.ជ
២.លោកជំទាវ **ឡុង សុនីតា** អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
តំណាង ឯកឧត្តម **កែវ រ៉េមី** ទេសរដ្ឋមន្ត្រី
៣.ឯកឧត្តម សន្តិបណ្ឌិត **ម៉ៅ ច័ន្ទតារា** រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ
៤.លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
៥.ឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការ តំណាង ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
៦.ឯកឧត្តម **រ៉ាត់ ចំរើន** រដ្ឋលេខាធិការ តំណាង ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា
៧.ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
៨.លោកជំទាវ **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ
៩.ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** អគ្គស្នងការរងនគរបាលជាតិ

ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ដែលជាសមាជិក គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អង្គទូតនានាប្រចាំព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គនាយករង តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ឯកឧត្តម លោកជំទាវ អភិបាល អភិបាលរង ស្នងការ ស្នងការរង រាជធានី/ខេត្ត ប្រធាន និងតំណាងអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ **សរុបចំនួន៖ ៣៩២ រូប ស្រី ១៥៨ រូប** ។



Scanned with CamScanner

## II.មតិស្វាគមន៍ និងរបាយការណ៍សង្ខេប

ជាកិច្ចចាប់ផ្ដើម **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ **គ.ជ.ប.ជ** បានមានមតិស្វាគមន៍ និងរបាយការណ៍សង្ខេប **ស្ដីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។** ក្នុងនាមអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **លោកជំទាវ** បានគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានដ៏ឧត្តុង្គឧត្តម **ឯកឧត្តមអភិសន្តិបណ្ឌិត** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ គ.ជ.ប.ជ ព្រមទាំងអង្គពិធីទាំងមូល ។ **លោកជំទាវ** បានមានប្រសាសន៍បន្តថា គិតត្រឹមឆ្នាំ២០២៣នេះ គឺជា **ខួប ១០ឆ្នាំ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)** ដែលបង្កើតឡើងដោយព្រះរាជក្រឹត្យ លេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ តាំងពីពេលដែលយន្តការមួយនេះ ត្រូវបានកែសម្រួលពី គណៈកម្មាធិការជាតិ ដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ហៅកាត់ថា «**ប.ជ.រ.ព.ភ**» មានសមាជិក ១៧ក្រសួង ទៅជាគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស «គ.ជ.ប.ជ» មាន ២២ក្រសួង និង ៥អគ្គនាយកដ្ឋានជំនាញជាសមាជិក និងបានផ្លាស់ប្ដូររបៀបរបបការងារ ពីលេខាធិការដ្ឋានមួយ ដែលមានសមាសភាពចម្រុះក្រសួង ទៅជាការបង្កើតអគ្គលេខាធិការដ្ឋានមួយ ដែលមានរចនាសម្ព័ន្ធ និងទីតាំងការងារជាក់លាក់បម្រើគណៈកម្មាធិការជាតិយ៉ាងពេញលេញ។ ក្នុងរយៈពេល ១០ឆ្នាំកន្លងទៅនេះ ទាំងរាជរដ្ឋាភិបាល និងទាំងដៃគូមិនមែនរដ្ឋា ភិបាលជាតិ និងអន្តរជាតិ បាននាំគ្នាប្រឹងប្រែងអស់ពីសមត្ថភាព ក្នុងការលុបបំបាត់នូវឧក្រិដ្ឋកម្មមួយនេះ ។ **លោកជំទាវ** បានបញ្ជាក់ជូនថា ឆ្នាំ២០២៣នេះ ក៏ជាឆ្នាំចុងក្រោយ នៃការអនុវត្ត ផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ០៥ឆ្នាំ (២០១៩-២០២៣) ។ បច្ចុប្បន្ននេះ គណៈកម្មាធិការជាតិ គ.ជ.ប.ជ បាន និងកំពុងរៀបចំចងក្រងផែនការយុទ្ធសាស្ត្រជាតិបន្ត ៥ឆ្នាំទៅមុខទៀត សម្រាប់អនុវត្តពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ ដែលនឹងត្រូវបានបញ្ចប់ នាពេលឆាប់ៗនេះ ។

**លោកជំទាវ** មានប្រសាសន៍អំពីស្ថានភាពទូទៅ ដែលជាហេតុនាំឲ្យកើតមាននូវអំពើជួញដូរមនុស្ស បណ្ដាលមកពី ផលប៉ះពាល់ នៃវិបត្តិសេដ្ឋកិច្ច សង្គម នយោបាយ ជាសាកល ដែលបណ្ដាលមកពីវដ្ដ នៃធម្មជាតិ មានជាអាទិ៍ ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី បម្រែបម្រួលអាកាសធាតុ ការកើនឡើងនូវ ខ្យល់កខ្វក់ ការឡើងកំដៅ ភ្លើងឆេះព្រៃ...។ល។ និងផលប៉ះពាល់ពីសង្គ្រាមប្រដាប់អាវុធ ការរាតត្បាតនៃជំងឺឆ្លង ជាពិសេស កូវីដ-១៩ និងមេរោគបំប្លែងថ្មីជាដើម បានបង្កឲ្យមានគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ ដល់ជីវិតមនុស្សលើផែនដី គ្រប់វ័យ គ្រប់ភេទ គ្រប់ជាតិសាសន៍ គ្រប់ស្ថានភាព និងគ្រប់ទីកន្លែង ។ ឆ្លៀតក្នុងស្ថានភាពដ៏ប្រឈមនេះ ធ្វើឲ្យក្រុមទុច្ចរិត និងបណ្ដាញរបស់ខ្លួន បានព្យាយាមរកគ្រប់មធ្យោបាយ បង្កើតនូវបទល្មើសថ្មីៗ ព្រមជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាទំនើប សម្រាប់ទាក់ទាញជនរងគ្រោះ ឱ្យធ្លាក់ចូលក្នុងកលល្បិចទុច្ចរិត ដើម្បីបម្រើមហិច្ឆតារបស់ខ្លួន ដែលបង្កឱ្យមានផលប៉ះពាល់យ៉ាងធំធេងលើជនរងគ្រោះទាំងក្នុង និងក្រៅប្រទេស ។

ជាថ្មីម្ដងទៀត **លោកជំទាវ** បានមានប្រសាសន៍ថ្លែងអំណរគុណ និងគោរពជូនពរ ជូនចំពោះ **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន** គ.ជ.ប.ជ ព្រមទាំង លោកជំទាវកិត្តិបណ្ឌិត រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងអង្គពិធីទាំងមូល សូមជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

## III.ប្រសាសន៍សំណេះសំណាល និងអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់

**ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន **គ.ជ.ប.ជ** មានប្រសាសន៍សំណេះសំណាលក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ស្ដីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៣ និងលើកទិសដៅការងារ ឆ្នាំ២០២៤ នាពេលនេះថា ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និង



Scanned with CamScanner

ក្នុងនាមជាប្រធាន គណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស សូមសម្តែងនូវអំណរសាទរ និងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះ ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន អង្គភាព អភិបាល អភិបាលរងរាជធានី ខេត្ត កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ឯកឧត្តម លោកជំទាវតំណាងអង្គទូតនានានៃបណ្តាប្រទេសប្រចាំនៅកម្ពុជា តំណាងអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ សមាជិក សមាជិកា និងភ្ញៀវកិត្តិយស ដែលបានអញ្ជើញមកចូលរួមយ៉ាងច្រើនកុះករ ញ៉ាំងឱ្យពិធីនេះរឹតតែមានភាពអធិកអធមទ្វេឡើងទៀត ។

**ឯកឧត្តមអភិសន្តិបណ្ឌិត** បានមានប្រសាសន៍លើកឡើងថា ឆ្នាំ២០២៣ កន្លងមកនេះ ផលប៉ះពាល់នៃជំងឺរាតត្បាត សង្គ្រាមស៊ីវិល និងសង្គ្រាមប្រឈមមុខដាក់គ្នា រវាងបណ្តាប្រទេសដែលមានខឿនសេដ្ឋកិច្ចរីកចម្រើន ជឿនលឿន ដែលជាប់ភូមិផងរបងជាមួយ រហូតមានការប្រើប្រាស់អាវុធយុទ្ធភ័ណ្ឌកាន់តែទំនើប និងសាហាវឃោរឃៅបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ អាយុជីវិតមនុស្ស សត្វ ធម្មជាតិដ៏ស្រស់បំព្រង បានដាក់សម្ពាធដល់ភាពរីកចម្រើននៃវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គម ជាអន្តរជាតិ និងបានបង្កឲ្យធម្មជាតិប្រែប្រួលមិនប្រក្រតី ហើយបានបង្កើតជាគ្រោះមហន្តរាយដល់ភពផែនដី នៅទូទាំងពិភពលោក គួរឱ្យព្រួយបារម្ភ ។ ទន្ទឹមនឹងនោះ វិធានការនៃការស្តារសេដ្ឋកិច្ច និងការរក្សាស្ថេរភាពសង្គម បានធ្វើឱ្យប្រទេសមួយចំនួនខិតខំប្រកួតប្រជែង ដណ្តើមទីផ្សារ សេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយរៀងៗខ្លួន ដោយជ្រុលនិយម មិនគិតពីគោលការណ៍កិច្ចសហប្រតិបត្តិការ គោរពអធិបតេយ្យភាពគ្នា និងការគាំទ្រគ្នាទៅវិញទៅមករវាងប្រទេសតូច ប្រទេសធំ ដែលនាំឲ្យមានផលជះជាអវិជ្ជមាន ទៅលើប្រទេសដែលមានលទ្ធភាពតិច ឱ្យប្រឈមនឹងការលំបាកកាន់តែខ្លាំង ស្ថានភាពដ៏ប្រឈមនេះ បានបង្កជាឱកាសល្អសម្រាប់ជនល្មើស ឲ្យកាន់តែមានលទ្ធភាពក្នុងការបង្កើតបទល្មើស ពង្រីកបណ្តាញ ធ្វើសកម្មភាពឧក្រិដ្ឋកម្មលើមនុស្សជាតិ គ្រប់ទីកន្លែង និងដោយមធ្យោបាយប្លែកៗ កាន់តែទំនើប ផ្អែកលើការរីកចំរើនដ៏ឆាប់រហ័សនៃវិស័យបច្ចេកវិទ្យា ។ ជាការពិតដែលថា គ្មានប្រទេសណាមួយដែលគេចផុតពីការអុកឡុករំខានពីបណ្តាញឧក្រិដ្ឋជនឡើយ ហេតុនេះហើយ បានជារាជរដ្ឋាភិបាលកម្ពុជា តែងអំពាវនាវឱ្យប្រទេសទាំងអស់រួមសហការគ្នា និងរិះរកគ្រប់មធ្យោបាយ ដើម្បីប្រយុទ្ធប្រឆាំងសត្រូវរួម គឺ «**អំពើឧក្រិដ្ឋកម្មឆ្លងដែនគ្រប់រូបភាព រួមទាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់**» ដើម្បីពង្រឹងសន្តិសុខ សុវត្ថិភាព ក្នុងតំបន់ និងក្នុងពិភពលោក ។ យើងមិនអាចមើលបំណាំគ្នា និង សាចទឹកដាក់គ្នាទៅវិញទៅមកបានឡើយ ។ ដូច្នេះ សកម្មភាពប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានបណ្តាញចាត់តាំង ដ៏ស្មុគ្រស្មាញបែបនេះ ពិតជាមិនអាចលុបបំបាត់បានដោយប្រទេសណាមួយតែឯងបានឡើយ ហើយទាមទារឱ្យមានកិច្ចសហការយ៉ាងសកម្ម មិនចាំតែស្តីបន្ទោស ដាក់បន្ទុកដោយមិនបានជួយរួមចំណែកបង្ការ ទប់ស្កាត់ ការពារ បានឡើយ ។ យើងត្រូវការកិច្ចសហការដែល រឹងមាំ និងស្មោះត្រង់ ដើម្បីទប់ស្កាត់ និងបំបាត់ប្រសិទ្ធភាពបទល្មើស និងបំបែកបណ្តាញជនល្មើស ដែលនៅរាយប៉ាយតាមបណ្តាប្រទេសតូច ធំនានា ក្នុងតំបន់ និងនៅលើពិភពលោក ។ **ឯកឧត្តមអភិសន្តិបណ្ឌិត** បានលើកឡើងថា ព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០២៣ ក៏មានកាតព្វកិច្ចជាច្រើនដែលរាជរដ្ឋាភិបាលត្រូវតែធ្វើឲ្យបានសម្រេចជាចាំបាច់ ក្នុងនាមជាប្រទេសប្រកាន់របបប្រជាធិបតេយ្យ សេរី ពហុបក្ស នោះគឺការបោះឆ្នោត ជ្រើសរើស និងតែងតាំងរដ្ឋសភា និងរាជរដ្ឋាភិបាល នីតិកាលទី៧ ហើយក៏ត្រូវបានអនុវត្តដោយសម្រេចបាននូវជោគជ័យដ៏ធំធេង និងបានរៀបចំគោលនយោបាយសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព បន្តវេនពីរាជរដ្ឋាភិបាលនីតិកាលទី៦ គឺគោលនយោបាយជាតិបញ្ចកោណដំណាក់កាលទី១ អាណត្តិទី៧ ក្នុងនោះ រាជរដ្ឋាភិបាល នៅតែកំណត់អាទិភាពខ្ពស់ ក្នុងការរក្សាស្ថេរភាពនយោបាយ ម៉ាក្រូសេដ្ឋកិច្ច និងសន្តិសុខសុវត្ថិភាពសង្គម ឱ្យបានជាដាច់ខាត ដើម្បីរក្សាឱ្យបានខឿនឯករាជ្យជាតិ ការអភិវឌ្ឍន៍ និងឆន្ទៈមោះមុតក្នុងការចូលរួមកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងជាមួយអន្តរជាតិ ក្នុងការដោះស្រាយបញ្ហារួម ។

**ឯកឧត្តអភិសន្តិបណ្ឌិត** មានប្រសាសន៍បញ្ជាក់ថា នៅចុងឆ្នាំ២០២២ និងដើមឆ្នាំ២០២៣ អំឡុងពេលដែលរាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមដាក់ចេញនូវផែនការប្រតិបត្តិការ បង្កើនការបង្ក្រាបអំពើជួញដូរមនុស្សគ្រប់ទម្រង់ ព័ត៌មានដែលទទួលបានពីគ្រប់មជ្ឈដ្ឋាន បានបង្ហាញពី សកម្មភាពលាក់បំពួននូវបទល្មើស ដែលមានទម្រង់ផ្សេងៗ រួមទាំងអំពើចាប់ជំរិត ការងារដោយបង្ខំ ការបង្ខាំង និងឈានដល់ការជួញដូរមនុស្ស ដែលត្រូវបានរក



Scanned with CamScanner

ឃើញ ប្រមាណជាង ១៥០ករណី ក្នុងចំណោម ជិត១០០០ករណីដែលបានរាយការណ៍ ។ ក្រៅពីនេះ ករណីសេសសល់ដទៃទៀតត្រូវបានរកឃើញថា មិនមែន ជាជនរងគ្រោះដោយអំពើជួញដូរមនុស្សឡើយ តែគឺជាករណីដែលមានការក្លែងបន្លំជាជនរងគ្រោះ ដើម្បីបិទបាំង ភាពខុសច្បាប់របស់ខ្លួន ដែលចង់គេចវេសពីការទទួលខុសត្រូវ ក្នុងបទល្មើសអន្តោប្រវេសន៍ បទល្មើសឧក្រិដ្ឋដែលប៉ុនប៉ងប្រព្រឹត្តនៅកម្ពុជា ឬការលាក់ខ្លួនធ្វើការងារដោយមិនមានការអនុញ្ញាតតែប៉ុណ្ណោះ ។ លទ្ធផលជាក់ស្តែង ដែលកម្លាំងសមត្ថកិច្ចបានធ្វើប្រតិបត្តិការ គិតពីខែសីហា ឆ្នាំ២០២២ ដល់ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣ រយៈពេល១ឆ្នាំ យើងទទួលបានសំណើ ឬសេចក្តីរាយការណ៍ ពីគ្រប់មជ្ឈដ្ឋាន ចំនួន ១.០៤៧ករណី ដែលក្នុងនោះ សេចក្តីរាយការណ៍បានបញ្ជាក់ថា មានមនុស្សចំនួន ២,៥៣៧នាក់ មាន២០សញ្ជាតិ ។ បន្ទាប់ពីបានធ្វើប្រតិបត្តិការរុករក ជាក់ស្តែង រកឃើញថា មាន ១,០១១ករណី ដែលមានមនុស្ស ១,៥៦៩នាក់ លើ ១៤សញ្ជាតិ ក្នុងនោះ មានជនសង្ស័យដែលត្រូវបានឃាត់ខ្លួន ១៤២នាក់ មាន ០៤សញ្ជាតិ(ចិន១១០នាក់ ខ្មែរ ១៧នាក់ វៀតណាម១២នាក់ និងថៃ០៣នាក់) ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬជាជនបង្ក ក្នុងករណី ចាប់បង្ខំឲ្យធ្វើការងារផ្ទុយពីឆន្ទៈ ការប្រើហិង្សា ការបំពានកិច្ចសន្យាការងារ...។ល។ ផ្អែកតាមភ័ស្តុតាង និងសកម្មភាពដែលបានកំណត់តាមច្បាប់ថាជាបទល្មើស រាជរដ្ឋាភិបាលបានសម្រេចបិទជាស្ថាពរ ០៥ក្រុមហ៊ុន រួមមាន (Galaxy World, ឆាងធឹង ស៊ិនហ័រខឺ Mountant, ជិងឆាយ៥ និង ប៉ាវយ៉ុង តិចណូឡូស៊ី) ផ្អាកអាជីវកម្ម និងបន្តស្រាវជ្រាវក្រុមហ៊ុនចំនួន ០៤ក្រុមហ៊ុន ( Be Change, International Intertainment, លីស៊ីង ហ័ងគន និងរស្មីមង្គល (K99))។

**ឯកឧត្តមអភិសន្តិបណ្ឌិត** មានប្រសាសន៍បន្តថា រហូតមកដល់ដើមឆ្នាំ២០២៤ នេះ រាជរដ្ឋាភិបាល មិនបានបោះបង់ការខិតខំប្រឹងប្រែង ដើម្បីបោសសម្អាតបទល្មើសឡើយ ប្រតិបត្តិការនៅតែបន្តដូចភ្លៀងរលឹម ហើយ លទ្ធផល នៃប្រតិបត្តិការបានបង្ហាញថា ភាគច្រើន នៃការផ្សព្វផ្សាយ មានលក្ខណៈបំផ្លើស មិនមែនជាការពិត រហូតដល់ទៅជាង ៨០ភាគរយ ។ ជនជាតិខ្លះបានបង្កើតឈុតឆាកដើម្បីបន្លំភ្នែក សាធារណៈមតិ ឲ្យគេមើលឃើញថា កម្ពុជា ជាកន្លែងប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ដែលជាចេតនារាំងស្ទះដល់វិស័យទេសចរណ៍ ធ្វើឱ្យអ្នកវិនិយោគ ភ័យខ្លាចមិនមកកម្ពុជា និងធ្វើឱ្យបណ្តាប្រទេសក្នុងពិភពលោកចោទប្រកាន់កម្ពុជា ថាជាកន្លែងដែលពោរពេញដោយបទល្មើស ដែលត្រូវដាក់សម្ពាធលើកម្ពុជាទៅវិញ ។

**ឯកឧត្តមអភិសន្តិបណ្ឌិត** មានប្រសាសន៍បញ្ជាក់ម្តងទៀតថា ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស យើងមិនដែលបដិសេធថា កម្ពុជាមិនមានបទល្មើសទេ ហើយក៏តែងតែបង្ហាញអំពីកង្វល់ និងប្រឹងប្រែងបោសសម្អាតដោយដាក់ចេញគ្រប់វិធានការ ដើម្បីលុបបំបាត់បទល្មើសទាំងនោះ ។ ទន្ទឹមនឹងនោះ យើងតែងអំពាវនាវដល់បណ្តាប្រទេសក្នុងតំបន់ និងប្រទេសពាក់ព័ន្ធ ឱ្យរួមសហការគ្នាបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស ដែលកំពុងតែកើតមានទៅលើប្រជាជនយើងទាំងអស់គ្នា មិនថាជាតិសាសន៍ណាឡើយ ។ វត្តមានជនបរទេសជាច្រើនសញ្ជាតិ ដែលមាននៅព្រះរាជាណាចក្រកម្ពុជា ដែលបាន និងកំពុងស្ថិតក្នុងស្ថានភាពអូសទាញដោយខុសច្បាប់ចូលមកកម្ពុជា ឬចូលមកដោយចេតនាផ្ទាល់ខ្លួន គេចវេសពីការទទួលខុសត្រូវផ្នែកច្បាប់ បានបញ្ជាក់ថា ការបង្ការទប់ស្កាត់ ឬបង្ក្រាបសកម្មភាពជនល្មើស នៅក្នុងបណ្តាប្រទេសទាំងនោះ មិនទាន់មានប្រសិទ្ធភាពនៅឡើយទេ ។ ហេតុនេះហើយ ទើបយើងទាំងអស់គ្នាត្រូវតែខិតខំបន្តទៀត ដើម្បីឲ្យកម្លាំង នៃការរួបរួមរបស់យើង អាចគ្របដណ្តប់ទៅលើបណ្តាញជនល្មើស ដែលកំពុងតែធ្វើសកម្មភាពគ្រប់ទីកន្លែង តាមគ្រប់មធ្យោបាយ ។

**ឯកឧត្តមអភិសន្តិបណ្ឌិត** មានប្រសាសន៍លើកឡើងបន្តថា នៅក្នុងនីតិកាលទី៧ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានតែងតាំងថ្មី នៅតែបន្តប្តេជ្ញាចិត្តមោះមុត ក្នុងការស្រាវជ្រាវ បង្ក្រាបបទល្មើសគ្រប់ទម្រង់ ក្នុងព្រះរាជាណាចក្រកម្ពុជា និងមិនអនុញ្ញាតឱ្យជនល្មើស ពួនសម្ងំប្រើប្រាស់ទឹកដីកម្ពុជា ដើម្បីសម្រេចនូវមហិច្ឆិតាទុច្ចរិត រំលោភលើអធិបតេយ្យភាព ឯករាជ្យភាព និងបំផ្លាញសន្តិភាពជាតិឡើយ ។ រាជរដ្ឋាភិបាលកម្ពុជាសូមអំពាវនាវដល់បណ្តាប្រទេសជាមិត្ត បើកចិត្តទូលាយ រួមសហការគ្នាដោយស្មោះត្រង់ ក្នុងការការពារសុវត្ថិភាព



Scanned with CamScanner

ពលរដ្ឋយើងទាំងអស់គ្នា និងគាំទ្រគ្នាទៅវិញទៅមកលើគ្រប់វិស័យ ដើម្បីផលប្រយោជន៍រួម ។ រាជរដ្ឋាភិបាលកម្ពុជានឹងខិតខំពង្រឹងសមត្ថភាពខ្លួនឯង ដើម្បីបំពេញចន្លោះខ្វះខាតដែលមានកន្លងមក ដើម្បីកសាងនូវភាពរឹងមាំសម្រាប់ការចូលរួមកិច្ចសហការទ្វេភាគី ពហុភាគី ក្នុងការរក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ក្នុងតំបន់ និងជាមួយបណ្តាប្រទេសនានាឱ្យកាន់តែខ្លាំងក្លា ។

ទន្ទឹមនឹងបរិបទ នៃការចាប់ផ្តើមសកម្មភាពរបស់គ្រប់ក្រសួងស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងនីតិកាលថ្មីនេះ **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** បានស្នើ និងផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ដូចខាងក្រោម៖

១-ក្រសួង ស្ថាប័ន អង្គភាពជាសមាជិក សមាជិកានៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គប្បីរៀបចំ និងពង្រឹងឡើងវិញទាំងសមាសភាព ទាំងសមត្ថភាពតាមខ្សែបណ្តោយរបស់ខ្លួន ដោយចាត់តាំងមន្ត្រីទទួលខុសត្រូវច្បាស់លាស់ និងសហការជាមួយអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលដឹកនាំដោយ **លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ ក្នុងការដឹកនាំសម្របសម្រួល រធ្វើការបណ្តុះបណ្តាលឡើងវិញ អំពីតួនាទី ភារកិច្ច ការទទួល ខុសត្រូវតាមវិស័យដើម្បីចូលរួមក្នុងការងារប្រឆាំងការជួញដូរមនុស្សឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

២-រៀបចំផែនការ ផ្អែកលើយុទ្ធសាស្ត្រ ដោយមានគោលការណ៍ វិធានការ ច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការវាស់វែងលទ្ធផល នៃការអនុវត្តសកម្មភាព តាមខែ ត្រីមាស ឆមាស និងឆ្នាំ ។

៣-ជម្រុញអនុវត្តវិធានការ គ្រប់គ្រងលំហូរឆ្លងកាត់ព្រំដែន ទាំងផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ដោយកំណត់បទល្មើសឱ្យបានជាក់លាក់ និងជួយជនរងគ្រោះឱ្យបានទាន់ពេលវេលា ។

៤-បន្តជំរុញកិច្ចសហការជាមួយប្រទេសជិតខាង និងប្រទេសពាក់ព័ន្ធ តាមកិច្ចព្រមព្រៀង ឬអនុស្សរណៈដែលមានស្រាប់ ឬបង្កើតឲ្យមានជាមួយបណ្តាប្រទេស ដែលពាក់ព័ន្ធ ងាយស្រួលក្នុងការពង្រឹងកិច្ចសហការ ក្នុងការបង្ការ បង្ក្រាប សង្គ្រោះ ផ្តន្ទាទោសជនល្មើស និងគាំពារជនរងគ្រោះ កន្លងមក ប្រទេសឡាវ និងម៉ាឡេស៊ី នៅមិនទាន់មានអនុស្សរណៈ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយកម្ពុជានៅឡើយទេ ។

**ឯកឧត្តមអភិសន្តិបណ្ឌិត** មានប្រសាសន៍ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តម លោកជំទាវ តំណាងបណ្តាប្រទេសពាក់ព័ន្ធ និងតំណាងទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលទាំងអស់ដែលបាន និងកំពុងយកចិត្តទុកដាក់សហការ គាំទ្រ និងចូលរួមសកម្មភាពជាមួយរាជរដ្ឋាភិបាល ក្នុងការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងតែងតែនាំគ្នា ពុះពារឧបសគ្គដោះស្រាយបញ្ហាគ្រប់គ្រាដែលមានទុក្ខលំបាក។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សូមថ្លែងអំណរគុណ និងសូមវាយតម្លៃខ្ពស់ ចំពោះគ្រប់កិច្ចខិតខំ ប្រឹងប្រែងទាំងអស់របស់ ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ និងមន្ត្រីជំនាញគ្រប់លំដាប់ថ្នាក់ នៃបណ្តាក្រសួង ស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាល គ្រប់រាជធានី ខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលបានបំពេញភារកិច្ចដោយមិនខ្លាចនឿយហត់ ប្រកបដោយស្មារតីទទួល ខុសត្រូវ និងភាពច្នៃប្រឌិត សំដៅការពារឱ្យបាននូវឯកភាពជាតិ អធិបតេយ្យភាព ការគោរពសិទ្ធិមនុស្ស សន្តិសុខ ស្ថិរភាពនយោបាយ និងវឌ្ឍនភាពសេដ្ឋកិច្ចក្នុងសង្គមជាតិយើង ។

ជាទីបញ្ចប់នេះ **ឯកឧត្តមអភិសន្តិបណ្ឌិត** មានប្រសាសន៍ថ្លែងអំណរគុណ និងជូនពរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ឯកឧត្តម លោកជំទាវ ភ្ញៀវជាតិ អន្តរជាតិ សហគមន៍អន្តរជាតិ សង្គមស៊ីវិលក្នុងស្រុក អ្នកសារព័ត៌មាន និងបងប្អូនជនរួមជាតិទាំងអស់ សូមមានសុខភាពល្អ និងសូមជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។



Scanned with CamScanner

IV.**ពិធីប្រគល់ប័ណ្ណសរសើរ និងការបំពាក់គ្រឿងឥស្សរិយយស**

**ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ ផ្តល់ជូននូវប័ណ្ណសរសើរជូនដល់ ឯកឧត្តម លោកជំទាវ ដែលជាអនុប្រធាន និងជាប្រធានក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័នទាំង០៦ និងឯកឧត្តម លោកជំទាវ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលជាសមាជិក គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រមទាំង ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី/ខេត្ត ទាំង២៥ ។ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ស សុខា** ក៏បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ផងដែរ ជូននូវគ្រឿងឥស្សរិយយសដល់ ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

ពិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានបញ្ចប់ដោយបរិយាកាសសោមនស្សរីករាយ និងស្និទ្ធស្នាលជាទីបំផុត ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃសុក្រ ៥រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤

**អ្នកធ្វើរបាយការណ៍**

វរៈសេនីយ៍ឯក. អ៊ុន សុខជា

**គោរពជូន**

**លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ**

មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

ថ្ងៃ...............ខែ............... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤

**ប្រធានក្រុមការងាររបាយការណ៍ និងដឹកជញ្ជូន**

ឧត្តមសេនីយ៍ឯក.**ខៀវ ចាន់ណា**

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃ...............ខែ............... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯកវេជ្ជ.ប៉ុណ្ណ សំខាន់

បានឃើញ

01/04/24

ជូ ប៊ុនអេង

Scanned with CamScanner